**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ ៖ ០០៤៩/១៧ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី១៩.ខែមេសា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង

## ស្តីពី

## ការលើកសម័យប្រឡងប្រជែងជ្រើសរើសសិស្ស-និស្សិតឱ្យចូលបម្រើការងារ ជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ឆ្នាំ ២០១៧

យោងលិខិតលេខ ៩៦៣ មស.ក្រខ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០១៧ របស់ក្រសួងមុខងារសាធារណៈ និងស្មារតីនៃកិច្ចប្រជុំថ្ងៃទី១០ ខែមេសាឆ្នាំ២០១៧ ក្រសួងអភិវឌ្ឍន៍ជនបទ មានកិត្តិយសសូមជម្រាបជូនបេក្ខជន បេក្ខនារី ដែលបានដាក់ពាក្យប្រឡងប្រជែងជ្រើសរើសសិស្ស-និស្សិត ចូលបម្រើការងារ ជាមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់ឆ្នាំ ២០១៧ ឱ្យបានជ្រាបថា សម័យប្រឡងចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១៧ ដែលគ្រោងរៀបចំនៅ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៧ ត្រូវបានលើកសម័យប្រឡង ទៅ **ថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១៧ វិញ នៅមណ្ឌលសាកលវិទ្យាល័យភូមិន្ទភ្នំពេញ** ។

ក្រសួងអភិវឌ្ឍន៍ជនបទ សូមអញ្ជើញបេក្ខជន បេក្ខនារីទាំងអស់ មកពិនិត្យមើលឈ្មោះ ដែលមានបិទផ្សាយនៅទីស្តីការក្រសួង ចាប់តាំងពី **ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧** តទៅ ដោយភ្ជាប់ជាមួយបណ្ណ័ដៃសុំសិទ្ធិប្រឡង ( បណ្ណ័ដៃទទួលពាក្យប្រឡង ) ។

**រដ្ឋលេខាធិការ**

**និងជាប្រធានគណៈកម្មការប្រឡង**

សួស គង់

ចម្លងជូន ៖
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួងអភិវឌ្ឍន៍ជនបទ ( ដើម្បីផ្សព្វផ្សាយ )
- ឯកសារ កាលប្បវត្តិ


អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 884 639
ទូរសារ (855) 23 991 117 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com